**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ១៩៤៧ មស.សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារពិនិត្យសំណុំឯកសារបេក្ខជនដែលត្រូវបានជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការសុខាភិបាលឆ្នាំ២០២១ ដើម្បីបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- យោងចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ របស់សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លើសំណើរួមគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ស្ដីពីផែនការក្របខណ្ឌឆ្នាំ២០២១
- យោងសេចក្ដីសម្រេចដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ របស់សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការផ្ដល់ក្របខណ្ឌបន្ថែមជាករណីពិសេសដល់ក្រសួងសុខាភិបាល សម្រាប់ឆ្នាំ២០២១ ចំនួន៣០០០កន្លែង ដើម្បីបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩
- យោងចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ របស់សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ២២៤ សខល ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល
- យោងលិខិតលេខ១១៩ សនប ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល ស្ដីពីសំណើសុំជ្រើសរើសមន្ត្រីចំនួន ៣០០០នាក់ ដែលកំពុងបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បញ្ចូលក្នុងក្របខណ្ឌសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួង។

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារពិនិត្យសំណុំឯកសារបេក្ខជនដែលត្រូវបានជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការសុខាភិបាលឆ្នាំ២០២១ ដើម្បីបម្រើការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **យក់ ប៊ុនណា** | រដ្ឋលេខាធិការប្រចាំការ | ប្រធាន |
| ២. ឯកឧត្តម **ថោ សេដ្ឋាណា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ហាឡា ណាំឆាន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម **ខៀវ ច័ន្ទប៊ុនធឿន** | រដ្ឋលេខាធិការ | អនុប្រធាន |



ផ្លូវវិត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

|  |  |  |
|---|---|---|
| ៥. ឯកឧត្តម **ទិន សុឃួន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦. លោកជំទាវ **ឆាយ គីមសុទ្ធី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧. ឯកឧត្តម **ស សាម៉ុឌី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨. ឯកឧត្តម **គង់ សុគី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩. ឯកឧត្តម **ឆាយ ឆត្រាឧុធ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០. ឯកឧត្តម **ពេជ្រ ទិដ្ឋាគន្ធី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១. ឯកឧត្តម **ហោច ពិសាល** | ទីប្រឹក្សា | សមាជិក |
| ១២. ឯកឧត្តមវេជ្ជ. **ជឿ សុខណាង** | ទីប្រឹក្សា | សមាជិក |
| ១៣. ឯកឧត្តម **ហាស់ ម៉ិនថុន** | អគ្គនាយក | សមាជិក |
| ១៤. ឯកឧត្តម **ឈុន សុជាតិ** | អគ្គនាយក | សមាជិក |
| ១៥. ឯកឧត្តម **យឿន សម្បត្តិ** | អគ្គនាយក | សមាជិក |
| ១៦. ឯកឧត្តម **ហែម មង្គលផល** | អគ្គាធិការ | សមាជិក |
| ១៧. ឯកឧត្តម **សុខ សំអាត** | អគ្គនាយករង | សមាជិក |
| ១៨. លោក **មាស ពេជ្រ** | អគ្គនាយករង | សមាជិក |
| ១៩. លោក **គីមស្ទង់ តេគង់** | អគ្គនាយករង | សមាជិក |
| ២០. លោក **ម៉ម ឡើត** | អគ្គនាយករង | សមាជិក |
| ២១. លោក **សួន រស្មី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២២. លោក **គង់ សុខក្តិភាព** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៣. លោក **ស៊ិន សុឃន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៤. លោក **ឡុង សារឿន** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៥. លោក **សូលី បណ្ណប៉ុក** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៦. លោក **សយ រតនៈ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ២៧. លោក **ផាន់ សុសត្យា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ២៨. លោក លោកស្រី ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត | | សមាជិក |

**ប្រការ២.** -

ក្រុមការងារនេះមានភារកិច្ច ដូចតទៅ៖

- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់សំណុំលិខិតបេក្ខជនម្នាក់ៗដែលផ្តល់ដោយក្រសួងសុខាភិបាល ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ សមស្របតាមលក្ខខណ្ឌ និងនីតិវិធីនៃការជ្រើសរើសបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការ
- ពិនិត្យលើការកំណត់ប្រភេទក្របខណ្ឌឱ្យបានសមស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ពិនិត្យ និងរៀបចំ បញ្ចូលមន្ត្រីសុខាភិបាលដែលបានជ្រើសរើសទៅតាមប្រភេទក្របខណ្ឌនីមួយៗ

- សហការជាមួយក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធដើម្បីសុំការគាំទ្រ និងជួយសម្រួលភារកិច្ច
- រៀបចំសំណុំឯកសាររបស់បេក្ខជនដែលបានជ្រើសរើស ដើម្បីរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈពិនិត្យ សម្រេចបញ្ចូលក្របខណ្ឌ។

**ប្រការ៣.-**

ក្រុមការងារត្រូវរៀបចំយន្តការការងារ និងបែងចែកការទទួលខុសត្រូវកិច្ចការអាទិភាពតាមផ្នែកនីមួយៗ ដើម្បីបង្កលក្ខណៈឱ្យការអនុវត្តភារកិច្ចខាងលើសម្រេចបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។

ក្រៅពីសមាសភាពដែលមានចែងក្នុងប្រការ១ខាងលើ ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីដទៃទៀតដើម្បីបំពេញការងារតាមការចាំបាច់។

**ប្រការ៤.-**

ក្រុមការងារត្រូវធ្វើរបាយការណ៍ជាប្រចាំ និងសុំយោបល់សម្រេចពីរដ្ឋមន្ត្រីលើបញ្ហាចាំបាច់បន្ទាន់។

**ប្រការ៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកសាលាភូមិន្ទរដ្ឋបាល គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ២០២១

រដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍"
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- រដ្ឋបាលរាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ដូចប្រការ ៥
- ឯកសារ កាលប្បវត្តិ